I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

ព្រះរាជក្រម លេខ នស/រកម/០១៩៤/០១ក

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជា ធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើររបស់នាយករដ្ឋមន្ត្រីទី ១ និងទី ២ ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៤

ត្រាស់បង្គាប់

ប្រកាសឱ្យប្រើ ច្បាប់ ដែលបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការ ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង អំពីឥណទានអភិវឌ្ឍន៍ សំរាប់ឆ្នាំ ១៩៩៤ ដែលបាន ស្រុះស្រួលគ្នា នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ រវាងព្រះរាជាណាចក្រកម្ពុជា និង សមាគមអន្តរជាតិអភិវឌ្ឍន៍ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ÷

ច្បាប់

ស្ដីពីការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងអំពីឥណទាន
អភិវឌ្ឍន៍សំរាប់ ឆ្នាំ ១៩៩៤ ដែលបានស្រុះស្រួលគ្នានៅ
ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៣

រវាង

ព្រះរាជាណាចក្រកម្ពុជា និង សមាគមអន្តរជាតិអភិវឌ្ឍន៍

មាត្រា ១ : ត្រូវបានអោយសច្ចាប័នទៅលើកិច្ចព្រមព្រៀង អំពីឥណទានអភិវឌ្ឍន៍សំរាប់ឆ្នាំ ១៩៩៤ ដែលសមាគមអន្តរជាតិអភិវឌ្ឍន៍ បានស្រុះស្រួលឱ្យព្រះរាជាណាចក្រកម្ពុជា ខ្ចីប្រាក់ចំនួន សែសិបប្រាំលានពីរសែន (៤៥.២០០.០០០) សិទ្ធិដកប្រាក់ ពិសេស (៤៥.២០០.០០០ S.D.R Special Drawing Rights) ដើម្បី ពង្រឹង សកម្មភាព សេដ្ឋកិច្ច ចំបងនិងនិតិសម្បទា នៃហេដ្ឋារចនាសម្ព័ន្ធ សាធារណៈជាអាទិ៍ ខាងវិស័យកសិកម្ម អប់រំ សុខាភិបាល អគ្គិសនី និង ដឹកជញ្ជូន ។

មាត្រា ២ : ត្រូវបានប្រកាសឱ្យប្រើជាប្រញាប់ នូវ ច្បាប់នេះ ។

ព្រះហស្តលេខា

ធ្វើនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៤

នរោត្តម សីហនុ

បានដាក់ថ្វាយទូល
និងសូមព្រះរាជហស្តលេខាដោយ
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
សម រង្ស៊ី

ឧត្តមព្រះរាជបញ្ជាដើម្បីអនុវត្ត
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហត្ថលេខា ហត្ថលេខា
នរោត្តម រណឫទ្ធិ ហ៊ុន សែន